រៀបចំដោយ

គាំទ្រដោយ

# ព្រឹត្តិបត្រពាណិជ្ជកម្ម
# iTrade Bulletin

## Inside

infographic

“ស្វែងយល់អំពីសក្តានុពលផលិតផលគ្រាប់ស្វាយចន្ទីនៅកម្ពុជា”

“Exploring the Potential of Cashew Nuts in Cambodia”

វ៉ុល ០១ | លេខ ០៥ | ខែ មិថុនា ឆ្នាំ២០២៥

VOLUME 01 | ISSUE 05 | JUNE 2025

# ស្វែងយល់អំពី ផ្នែកទី១

# សក្តានុពលផលិតផលគ្រាប់ស្វាយចន្ទីនៅកម្ពុជា

រៀបចំដោយ

គាំទ្រដោយ

សូមស្កេនដើម្បីទាញយក
ព្រឹត្តិបត្រពាណិជ្ជកម្ម

** ព័ត៌មានបន្ថែម,
សូមទាក់ទងមកកាន់លេខទូរស័ព្ទ
ទំនាក់ទំនងសាធារណៈ: ១២៦៦

## I.ព័ត៌មានមូលដ្ឋាន នៃគ្រាប់ស្វាយចន្ទីបកសំបក(កូដទំនិញ: ០៨០១៣២)

| | |
|---|---|
| ៤,១ ប៊ីលានដុល្លារ | ២០២០ |
| ៤,២៦ ប៊ីលានដុល្លារ | ២០២៤ |

កើនឡើង៣,៧៨%

ការនាំចូលគ្រាប់ស្វាយចន្ទីបកសំបក(កូដទំនិញ: ០៨០១៣២) លើទីផ្សារពិភពលោក ក្នុងឆ្នាំ២០២៤ មានទឹកប្រាក់សរុបចំនួន៤,២៦ ប៊ីលានដុល្លារ កើនឡើង៣,៧៨% បើធៀបនឹងឆ្នាំ២០២០ ដែលមានប្រមាណ៤,១ ប៊ីលានដុល្លារ។

### ១.ប្រទេសកំពូលទាំង៥ សម្រាប់ការនាំចូល និងនាំចេញគ្រាប់ស្វាយចន្ទីបកសំបក នៅកាន់ទីផ្សារពិភពលោក (២០២៤)

សម្រាប់ប្រទេសនាំចូល:




សម្រាប់ប្រទេសនាំចេញ:




ប្រភព: ITC(Trademap). Retrieved June 26, 2025 from https://www.trademap.org

### ២.អត្រាពន្ធគយ នៃគ្រាប់ស្វាយចន្ទីបកសំបកសម្រាប់ការនាំចូល(កូដទំនិញ: ០៨០១៣២)

គ្រាប់ស្វាយចន្ទីបកសំបក




| *ចិន | MFN | RCEP | ACFTA | CCFTA |
|---|---|---|---|---|
| | ១០% | ពី ១០% ដល់ 0% បន្ទាប់ពី១០ ឆ្នាំ | 0% | 0% |

ប្រភព: ITC(Trademap). Retrieved June 26, 2025 from https://www.trademap.org

សម្គាល់: ពន្ធនាំចូលទៅកាន់សហរដ្ឋអាម៉េរិកអាចប្រែប្រួលដោយសារតែពន្ធគយបដិការ របស់លោកប្រធានាធិបតី ដូណាល់ ត្រាំ ។

## II.ចំណុចសំខាន់ៗ នៃឧស្សាហកម្មគ្រាប់ស្វាយចន្ទីកម្ពុជា (២០២៤)

- ផលិតគ្រាប់ស្វាយចន្ទីធំជាងគេ
- ផលិតកម្ម
- ការនាំចេញគ្រាប់ស្វាយចន្ទីឆៅ
- តម្លៃនៃការនាំចេញគ្រាប់ស្វាយចន្ទីឆៅ
- ការនាំចេញគ្រាប់ស្វាយចន្ទីឆៅទៅកាន់វៀតណាម
- ផ្ទៃដីដាំដុះ

### ផលិតគ្រាប់ស្វាយចន្ទីធំជាងគេ

កម្ពុជាគឺជាប្រទេសផលិតគ្រាប់ស្វាយចន្ទីធំជាងគេទី២ របស់ពិភពលោក (១៧% នៃចំណែកផលិតកម្មពិភពលោកក្នុងឆ្នាំ២០២) បន្ទាប់ពីកូតឌីវ័រ (២៤% នៃចំណែកផលិតកម្មពិភពលោកក្នុងឆ្នាំ២០២៤)*

### ផលិតកម្ម

ផលិតកម្ម៖ ៨៥០.០០០ តោន/ឆ្នាំ**

# ស្វែងយល់អំពី ផ្នែកទី២

# សក្តានុពលផលិតផលគ្រាប់ស្វាយចន្ទីនៅកម្ពុជា

### ការនាំចេញគ្រាប់ស្វាយចន្ទីឆៅ

ការនាំចេញគ្រាប់ស្វាយចន្ទីឆៅ៖ ៨១៥.000តោន (៩៥%នៃគ្រាប់ស្វាយចន្ទីសរុប)(កើនឡើង+២១% ) ប្រាក់ចំណូលពីការនាំចេញ ៖ ១.១៥០ លានដុល្លារ(2024)(កើនឡើង+26,15%)**

### តម្លៃនៃការនាំចេញគ្រាប់ស្វាយចន្ទីឆៅ

តម្លៃនៃការនាំចេញគ្រាប់ស្វាយចន្ទីឆៅ៖ ១.៤១១ ដុល្លារ/តោន

### ការនាំចេញគ្រាប់ស្វាយចន្ទីឆៅទៅកាន់វៀតណាម

ការនាំចេញគ្រាប់ស្វាយចន្ទីឆៅទៅកាន់វៀតណាម៖ ៧៩៥.000តោន**

### ផ្ទៃដីដាំដុះ

ផ្ទៃដីដាំដុះ៖ ៧00.000 ហិកតា**

ប្រភព: * Report Cambodian Cashew Value Chain Analysis (December 2024)
**របាយការណ៍សមាគមគ្រាប់ស្វាយចន្ទីកម្ពុជាឆ្នាំ២០២៤

## III.បញ្ហាប្រឈមចំពោះឧស្សាហកម្មនេះ

បញ្ហាប្រឈម

- ១ សមត្ថភាពកែច្នៃមានកម្រិត
- ២ ការប្រែប្រួលតម្លៃ
- ៣ គម្លាតហេដ្ឋារចនាសម្ព័ន្ធ
- ៤ ហានិភ័យអាកាសធាតុ
- ៥ កង្វះធនធានហិរញ្ញវត្ថុ

### សមត្ថភាពកែច្នៃមានកម្រិត

ជាង ៩០% នៃ គ្រាប់ស្វាយចន្ទីរបស់កម្ពុជាត្រូវបាននាំចេញឆៅទៅវៀតណាម ដែលមានន័យថាឧស្សាហកម្មនេះខកខានការនាំចេញគ្រាប់ស្វាយចន្ទីកែច្នៃដែលមានតម្លៃខ្ពស់ និងប្រាក់ចំណេញខ្ពស់ ។

### ការប្រែប្រួលតម្លៃ

កសិករមានហានិភ័យនៅពេល ដែលតម្លៃសកលប្រែប្រួល

### គម្លាតហេដ្ឋារចនាសម្ព័ន្ធ

ការចំណាយខ្ពស់នៃភស្តុភារ និងអគ្គិសនី ក៏ដូចជាកង្វះគ្រឿងបរិក្ខារកែច្នៃទំនើប ធ្វើឱ្យអាជីវកម្មក្នុងស្រុកពិបាកបន្ថែមតម្លៃ ។

### ហានិភ័យអាកាសធាតុ

គ្រោះរាំងស្ងួត និងសត្វល្អិតគំរាមកំហែងដល់ទិន្នផល ដែលទាមទារការអនុវត្តកសិកម្មប្រកបដោយចីរភាព

### កង្វះធនធានហិរញ្ញវត្ថុ

កង្វះធនធានហិរញ្ញវត្ថុសម្រាប់វិស័យនេះ

## IV.គំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាល និងវិស័យឯកជន

▸ គោលនយោបាយជាតិស្តីពីគ្រាប់ស្វាយចន្ទី ឆ្នាំ២០២២-២០២៧៖

១ លើកកម្ពស់ទិន្នផលនៃការផលិត និងផលិតកម្ម ប្រកបដោយគុណភាពប្រកួតប្រជែង

២ ជំរុញការធ្វើឧស្សាហូបនីយកម្ម ដើម្បីបង្កើនតម្លៃបន្ថែមលើការប្រមូលផលនិងការកែច្នៃអនុផលគ្រាប់ស្វាយចន្ទីឱ្យសម្រេចបាន២៥% នៅឆ្នាំ២០២៧ និងយ៉ាងតិច៥០% នៅឆ្នាំ២០៣២

៣ ជំរុញការនាំចេញ តាមរយៈការធ្វើពិពិធកម្មទីផ្សារ ការផ្សារភ្ជាប់អន្តរវិស័យក្នុងការនាំចេញ កិច្ចសម្រួលពាណិជ្ជកម្ម ការកាត់បន្ថយថ្លៃដើម និងការលើកកម្ពស់ឧត្តមភាពលើទីផ្សារ

▸វិញ្ញាបនបត្រ និងចីរភាព៖ កិច្ចខិតខំប្រឹងប្រែងកំពុងដំណើរការ ដើម្បីជំរុញវិញ្ញាបនបត្រសរីរាង្គ និងពាណិជ្ជកម្មដោយយុត្តិធម៌ ក្នុងការជំរុញលទ្ធភាពទទួលបានទីផ្សារដែលមានតម្លៃខ្ពស់

**រៀបចំដោយ** **គាំទ្រដោយ**

សូមស្កេនដើម្បីទាញយក
ព្រឹត្តបត្រពាណិជ្ជកម្ម

** ព័ត៌មានបន្ថែម,
សូមទាក់ទងមកកាន់លេខទូរស័ព្ទទំនាក់ទំនងសាធារណៈ: ១២៦៦

# Exploring the Part1

# Potential of Cashew Nut in Cambodia

Organized by

Supported by

Scan to access iTrade Bulletin

** For more information, please contact the Ministry of Commerce Call center 1266

## I. Basic Information of Shelled Cashew Nut (HS code: 080132)

| | |
|---|---|
| USD 4.1 Billion | 2020 |
| USD 4.26 Billion | 2024 |

Increase of 3.78%

Imports of shelled cashew nuts (HS code: 080132) on the world market in 2024 totaled USD 4.26 Billion, an increase of 3.78% compared to 2020, which was approximately USD 4.1 Billion.

### 1.Top 5 Countries of Import and Export for shelled cashew nuts to world market (2024)

**FOR IMPORTERS:**




**FOR EXPORTERS:**




**Source:** ITC(Trademap). Retrieved June 26, 2025 from https://www.trademap.org

### 2.Tariff Rates of shelled cashew nuts for import (HS code: 080132)

**SHELLED CASHEW NUT**




| *CHINA | MFN | RCEP | ACFTA | CCFTA |
|---|---|---|---|---|
| | 10% | From 10% to 0% after 10 years | 0% | 0% |

**Source:** ITC(Trademap). Retrieved June 26, 2025 from https://www.trademap.org

**Note:** Import duties into the United States may change due to President Donald Trump's reciprocal tariffs.

## II.Key Highlights of Cambodia's Cashew Industry (2024)

- LARGEST CASHEW PRODUCER
- PRODUCTION
- EXPORT
- RAW CASHEW NUT EXPORT PRICE
- RAW CASHEW NUT EXPORT TO VIETNAM
- CULTIVATED AREA

**LARGEST CASHEW PRODUCER**

Cambodia is the world's 2nd-largest cashew producer (17% of the world's production share in 2024) after Côte d'Ivoire (24% of the world's production share in 2024)*

**PRODUCTION**

Production: 850,000 tons/year**

# Exploring the Part2
# Potential of Cashew Nut in Cambodia

**RAW CASHEW NUT EXPORT**

RCN Export: 815,000 Tons (95% of total cashew nut) (Increase +21%) Revenue from Export: USD 1,150 million (2024) (Increase +26.15%)**

**RAW CASHEW NUT EXPORT PRICE**

RCN export price: 1,411 USD /Ton

**RAW CASHEW NUT EXPORT TO VIETNAM**

RCN Export to Vietnam: 795,000 tons **

**CULTIVATED AREA**

Cultivated Area: 700,000 hectares**

**Source:** * Report Cambodian Cashew Value Chain Analysis (December 2024)
**Report of Cashew Nut Association of Cambodia in 2024

## III.Challenges Facing the Industry




**LIMITED PROCESSING CAPACITY**

Over 90% of Cambodia's cashews are exported raw to Vietnam, meaning the industry misses out on high-value and high-profit processed exports.

**PRICE VOLATILITY**

Farmers are at risk when global prices change

**INFRASTRUCTURE GAPS**

High costs of logistics and electricity, as well as a lack of modern processing facilities, make it hard for local businesses to add value.

**CLIMATE RISKS**

Droughts and pests threaten yields, requiring sustainable farming practices

**SCARCITY OF FINANCIAL RESOURCES**

Scarcity of financial resources for this sector

## IV.Royal Government and Private Sector Initiatives

▸ **National Cashew Policy 2022-2027:**

1. Improve production output and production with competitive quality
2. Promote industrialization to increase value added in cashew harvesting and processing to achieve 25% by 2027 and at least 50% by 2032
3. Promote exports through market diversification, cross-sector linkages in exports, trade facilitation, cost reduction, and promoting market superiority

▸ **Certification & Sustainability: Efforts are underway to promote organic and fair-trade certification, improving market access to premium markets**

**Organized by** **Supported by**

**Scan to access iTrade Bulletin**

** For more imformation, please contact the Ministry of Commerce Call center 1266

## សម្តេចធិបតីនាយករដ្ឋមន្ត្រី៖ កម្ពុជាផ្តល់ឱកាសវិនិយោគយ៉ាងទូលំទូលាយ

ថ្លែងក្នុងពិធីអបអរសាទរការដំណើរការជាផ្លូវការ ១ឆ្នាំ របស់សមាគមសហព័ន្ធអ្នកវិនិយោគកម្ពុជា និងពិធីពិសាភោជនាហារសាមគ្គី ឆ្នាំ២០២៥ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្ររាជធានីភ្នំពេញ សម្តេចធិបតីនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត សង្ឃឹមថា វិនិយោគិននឹងបន្តមកបណ្តាក់ទុននៅកម្ពុជា ហើយអ្នកទើបស្វែងរកឱកាសវិនិយោគអាចជ្រើសរើសវិនិយោគ និងតភ្ជាប់ខ្សែច្រវាក់ផលិតកម្មរវាងកម្ពុជា និងប្រទេសនានាជុំវិញពិភពលោក។ យោងតាមរបាយការណ៍របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងរយៈពេល៥ខែដំបូង នៃឆ្នាំ២០២៥ គម្រោងវិនិយោគសរុបចំនួន២៩៩ ត្រូវបានអនុម័តជាមួយនឹងទុនវិនិយោគសរុបចំនួន ៤,២ ប៊ីលានដុល្លារ។ បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤ មានការកើនឡើងនៃគម្រោងចំនួន១៣៧ ឬប្រហែល៩០% ខណៈដែលទុនវិនិយោគបានកើនឡើងជាង ១,៤ ប៊ីលានដុល្លារ ស្មើនឹងប្រមាណ៥២%។ *ប្រភព៖* Khmer Times

## លោកជំទាវ ចម និម្មល លើកទឹកចិត្តឱ្យមានការវិនិយោគពីកូរ៉េលើវិស័យសំខាន់ៗបន្ថែមទៀត

លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានលើកទឹកចិត្តវិនិយោគិនកូរ៉េ ឱ្យមកបណ្តាក់ទុន និងធ្វើអាជីវកម្មបន្ថែមទៀត ជាពិសេសលើវិស័យសក្តានុពល ដូចជា កសិកម្មទំនើប ឧស្សាហកម្មកែច្នៃម្ហូបអាហារ យានយន្ត អេឡិចត្រូនិក និងបច្ចេកវិទ្យាឌីជីថល។ លោកជំទាវ ក៏បានសង្កត់ធ្ងន់ផងដែរអំពីសារៈសំខាន់នៃការទាញយកអត្ថប្រយោជន៍ជាអតិបរមានៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-កូរ៉េ, កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ដែលប្រទេសទាំងពីរជាសមាជិក ដើម្បីជួយជំរុញកំណើនពាណិជ្ជកម្មទ្វេភាគីបន្ថែមទៀត។ តួលេខបានបង្ហាញថា ក្នុងរយៈពេលប្រាំខែដំបូងនៃឆ្នាំ២០២៥ ពាណិជ្ជកម្មរវាងកម្ពុជា និងកូរ៉េឈានដល់ជាង ៣៦២ លានដុល្លារ កើនឡើង១១% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ *ប្រភព៖* Khmer Times

## វិស័យមិនមែនកាត់ដេរមានកំណើនគួរឱ្យកត់សម្គាល់

ការនាំចេញផលិតផលមិនមែនកាត់ដេររបស់កម្ពុជាមានការកើនឡើងគួរឱ្យកត់សម្គាល់ ដែលជាសូចនាករដ៏រឹងមាំនៃយុទ្ធសាស្ត្រធ្វើពិពិធកម្មសេដ្ឋកិច្ចដ៏ជោគជ័យរបស់កម្ពុជា។ ផលិតផលមិនមែនកាត់ដេររួមមានគ្រឿងអេឡិចត្រូនិក គ្រឿងបន្លាស់រថយន្ត កង់ សំបកកង់រថយន្ត ស្បែក ប្លាស្ទិក និងផលិតផលឧស្សាហកម្មផ្សេងទៀត។ ទិន្នន័យពីក្រសួងពាណិជ្ជកម្មបានបង្ហាញថា ការនាំចេញទំនិញអេឡិចត្រូនិកនិងគ្រឿងបន្លាស់ មានចំនួន ២៨៧ លានដុល្លារ ក្នុងរយៈពេល ៥ ខែដំបូងនៃឆ្នាំនេះ កើនឡើង ២,៤% ធៀបនឹងឆ្នាំមុន។ គ្រឿងបន្លាស់រថយន្តនាំចេញរបស់ប្រទេសកម្ពុជាមានចំនួន ១១៧ លានដុល្លារ កើនឡើង ១៨,៣% កង់ ២៨៧ លានដុល្លារ កើនឡើង ៤៦,៩% ខ្សែភ្លើង និងខ្សែកាប ២៣២ លានដុល្លារ កើនឡើង ៨៣,៦% និងសំបកកង់រថយន្ត ៥៦០ លានដុល្លារ កើនឡើង ៨១%។ ទោះជាយ៉ាងណា ការនាំចេញបន្ទះសូឡាធ្លាក់ចុះខ្លាំងពីចំនួន ៩៩% មកត្រឹម ៣,៨៧ លានដុល្លារ ពី ៤១២ លានដុល្លារដែលបានកត់ត្រាក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ *ប្រភព៖* Khmer Times

## ការផលិតសំបកកង់ជំរុញកំណើននាំចេញផលិតផលក្នុងវិស័យយានយន្តជាង ១ប៊ីលានដុល្លារ

ទុនវិនិយោគក្នុងវិស័យយានយន្តកម្ពុជា គិតត្រឹមឆ្នាំ ២០២៤ មានប្រមាណ ៧៤៦ លានដុល្លារ ខណៈការនាំចេញមានទឹកប្រាក់ជាង ១,១ ប៊ីលានដុល្លារ ដែលភាគច្រើនបានមកពីការនាំចេញផលិតសំបកកង់រថយន្ត នេះបើតាម ឯកឧត្តម ស៊ុន ចាន់ថុល អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលបានគូសបញ្ជាក់អំពីវឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់នេះក្នុងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិដឹកនាំការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា។ លោកបានថ្លែងថា៖ ក្រោយពីបានដាក់ចេញនូវផែនទីបង្ហាញផ្លូវនាពេលកន្លងមក ការធ្វើពិពិធកម្មសេដ្ឋកិច្ចបានលេចចេញជាផ្លែផ្កាគួរជាទីមោទនៈ។ ជាក់ស្តែងនៅឆ្នាំ២០២៤ វិស័យយានយន្តកម្ពុជាទទួលបានទំហំទុនវិនិយោគប្រមាណ ៧៤៦លានដុល្លារ ខណៈការនាំចេញបានកើនឡើងដល់ប្រមាណ ១,១៤ប៊ីលានដុល្លារ គឺលើសពីផែនការសម្រាប់ឆ្នាំ ២០២៧។ *ប្រភព៖* Phnom Penh Post

## PM Says Cambodia Offers Ample Investment Opportunities

Speaking at the first anniversary of the Cambodia Confederation of Investors Association (CCIA) and the 2025 Solidarity Dinner at Koh Pich Convention and Exhibition Centre in Phnom Penh, Mr Hun Manet hoped that investors will continue to invest in Cambodia and that those who have just come to seek investment opportunities can choose to invest and connect production chains between Cambodia and other countries across the world. According to a report from the Council for the Development of Cambodia (CDC), in the first five months of 2025, a total of 290 investment projects were approved with a combined investment capital of $4.2 billion. Compared to the same period in 2024, this represents an increase of 137 projects, or about 90%, while investment capital rose by over $1.4 billion, equivalent to approximately 52%. ***Source: Khmer Times***

## Nimul Calls for More Korean Investment in Key Sectors

Minister of Commerce Cham Nimul encouraged Korean investors to invest and do more business, especially in potential sectors such as modern agriculture, food processing industry, automotive, electronics, and digital technology. She also emphasised the importance of taking maximum advantage of the Cambodia-Korea Bilateral Free Trade Agreement, the ASEAN-Korea Free Trade Agreement, and the Regional Comprehensive Economic Partnership Agreement of which both countries are members, to help further promote the growth of bilateral trade. Official figures showed that in the first five months of 2025, trade between Cambodia and Korea reached over $362 million, an increase of 11 percent compared to the same period last year. ***Source: Khmer Times***

## Non-Garment Sector Marks Significant Growth

Cambodia is experiencing a notable and sustained increase in the export of non-garment manufacturing products, a strong indicator of the Kingdom's successful economic diversification strategy. The non-garment manufacturing products include electronic components, auto parts, bicycle, car tyres, leather, plastic and other industrial products. Data from the Ministry of Commerce showed that the exports of electronic goods and parts amounted to $287 million in the first five months of this year, up 2.4% over that last year. The country's export vehicle parts amounted to $117 million, up 18.3%, bicycle $287 million, up 46.9%, electric cable and wire $232 million, up 83.6%, and car tyre $560 million, up 81%. Export of solar panels, however, saw a huge decrease of 99% to $3.87 million from $412 million recorded in the same period last year. ***Source: Khmer Times***

## Vehicle Industry Exports Exceed $1 Billion, Growth Driven by Tyre Manufacturing

As of 2024, investment in Cambodia's automotive sector reached approximately $746 million, while exports exceeded $1.1 billion, the majority of which came from tyre manufacturing. Sun Chanthol, first vice-president of the Council for the Development of Cambodia (CDC), highlighted this remarkable progress during the Executive Committee overseeing the implementation of the roadmap for the development of Cambodia's automotive and electronics sectors. "Following the launch of the roadmap, economic diversification has begun to bear promising fruit. Notably, in 2024, Cambodia attracted around $746 million in automotive investment, while exports surged to around $1.14 billion, surpassing targets initially set for 2027.
***Source: Phnom Penh Post***

## WTO ពិនិត្យលើតម្រូវការរបស់ LDC ផ្តោតអាទិភាពលើពាណិជ្ជកម្ម និងការអភិវឌ្ឍ

កិច្ចប្រជុំគណៈកម្មាធិការ អនាម័យ និងភូតគាមអនាម័យ (SPS) របស់ WTO សមាជិកបានយល់ព្រមដាក់ឱ្យដំណើរការក្រុមការងារតម្លាភាពរយៈពេលពីរឆ្នាំ ដោយចាប់ផ្តើមពីខែវិច្ឆិកាខាងមុខ ដើម្បីកែសម្រួលនូវការជូនដំណឹង SPS ការតាមដានមតិយោបល់ និងវេទិកា ePing ។ ប្រព័ន្ធប្រឹក្សា SPS ថ្មីក៏ត្រូវបានដាក់ឱ្យដំណើរការផងដែរ ដើម្បីគាំទ្រសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ និង LDC ជាមួយនឹងដំណាក់កាលសាកល្បង ពីខែមិថុនា ឆ្នាំ២០២៥ ដល់ខែមិថុនា ឆ្នាំ២០២៦។ កង្វល់ពាណិជ្ជកម្មជាក់លាក់ចំនួន ៥៦ (STCs) ត្រូវបានពិភាក្សារួមទាំងបញ្ហាថ្មីលើកាហ្វេ សណ្តែកដី បង្គា និងបញ្ជីការនាំចេញ។ STDF បានចែករំលែកបច្ចុប្បន្នភាព និងរបាយការណ៍ប្រចាំឆ្នាំ២០២៤ របស់ខ្លួន ដោយឆ្លុះបញ្ចាំងពីការងាររយៈពេលពីរទសវត្សរ៍ និងឱ្យស្របជាមួយយុទ្ធសាស្ត្រ ២០២៥-២០៣០។ ប្រភព៖ [WTO]

## គម្រោងវេទិកា TWIN អាចនឹងកាត់បន្ថយថ្លៃដើមពាណិជ្ជកម្មសកលបាន ២៥%

មូលនិធិ Trade Worldwide Information Network (TWIN) ដែលបានដាក់ឱ្យដំណើរការក្នុងខែឧសភា ឆ្នាំ២០២៥ មានគោលបំណងធ្វើឱ្យពាណិជ្ជកម្មសកលលោកមានលក្ខណៈឌីជីថលរលូន និងបរិយាបន្ន ។ វេទិកា TWIN បង្កើតឡើងដោយបច្ចេកវិទ្យាប្រភពបើកចំហ វិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ វាជួយបង្កើនអធិបតេយ្យភាពទិន្នន័យ តម្លាភាព និងអន្តរប្រតិបត្តិការ ដែលអាចកាត់បន្ថយតម្លៃពាណិជ្ជកម្មដល់ទៅ ២៥% និងបើកទូលាយនូវតម្លៃសេដ្ឋកិច្ចសរុបដល់ ១០ ទ្រីលានដុល្លារ។ គម្រោងនេះត្រូវបានសាកល្បងនៅអាហ្វ្រិកខាងកើត TWIN បានកាត់បន្ថយពេលវេលានៃនិតិវិធីបែបបទគយ និងការចំណាយលើពាណិជ្ជកម្មយ៉ាងខ្លាំង។ វេទិកានេះគាំទ្រពាណិជ្ជកម្មដោយមិនប្រើក្រដាស ផ្តល់អត្ថប្រយោជន៍ដល់អាជីវកម្មខ្នាតតូច និងលើកកម្ពស់បរិស្ថានប្រកបដោយនិរន្តរភាព។ ប្រភព៖ [World Economic Forum]

## ក្របខណ្ឌពាណិជ្ជកម្មអាម៉េរិក-ចិន បានព្រមព្រៀង និងព្រឹត្តិការណ៍ពាណិជ្ជកម្មអន្តរជាតិផ្សេងទៀត

សមាជិកបានផ្តោតលើអាទិភាពពាណិជ្ជកម្មសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) ពិនិត្យឡើងវិញនូវសំណើស្តីពីការចាកចេញពី LDC ការចូលជាសមាជិក និងអនាគតនៃកម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្មពាណិជ្ជកម្ម (EIF)។ សមាជិកបានចែករំលែកបទពិសោធន៍លើការវិនិយោគបៃតង ហិរញ្ញប្បទានអាកាសធាតុ និងជំនួយសម្រាប់ពាណិជ្ជកម្មជាមួយប្រទេសកាណាដា ជប៉ុន ចិន និងឡាវ ដែលបង្ហាញពីការគាំទ្រនេះ។ ការកំណត់ ស្តីពីប្រព្រឹត្តិកម្មពិសេសនិងដោយឡែកក្រោមកិច្ចព្រមព្រៀងកសិកម្ម ក៏ត្រូវបានលើកមកពិភាក្សាផងដែរ។ របាយការណ៍ជំនួយបច្ចេកទេសរបស់ WTO ឆ្នាំ២០២៤ បានកត់សម្គាល់សកម្មភាពដែលបានពង្រីកនៅក្នុងការវាយតម្លៃពន្ធគយ ការផ្សព្វផ្សាយការសិក្សា និងការចូលជាសមាជិករបស់ WTO ទោះបីជាមានឧបសគ្គថវិកាក៏ដោយ។ សមាជិកបានយល់ព្រមពង្រឹងទំនាក់ទំនងអភិវឌ្ឍន៍ពាណិជ្ជកម្ម និងស្វាគមន៍ការបន្តការចូលរួម។ ប្រភព៖ [World Economic Forum]

## អ្វីទៅជាច្រក (Strait of Hormuz) និងហេតុអ្វីបានជាវាមានសារៈសំខាន់ចំពោះពាណិជ្ជកម្មសកល?

ច្រកដឹកជញ្ជូន ហ័រមុស ជាច្រកសមុទ្រមានទទឹងប្រហែល ៣៣គីឡូម៉ែត្រវាងប្រទេសអូម៉ង់ និងអ៊ីរ៉ង់ ជាផ្លូវទឹកពាណិជ្ជកម្មសំខាន់បំផុតមួយរបស់ពិភពលោក។ មានប្រេងឥន្ធនៈជាង ១/៥ នៃប្រេងសកល ប្រហែល ២០លានបារ៉ែលក្នុងមួយថ្ងៃឆ្លងកាត់ច្រកនេះ។ វាភ្ជាប់ឈូងសមុទ្រពែរ្ស៊ីទៅសមុទ្រអូម៉ង់ និងសមុទ្រអារ៉ាប៊ី, សភាអ៊ីរ៉ង់បានអនុម័តច្បាប់មួយដើម្បីបិទច្រកនេះ ក្នុងការឆ្លើយតបនឹងការវាយប្រហារពីអាកាសរបស់អាម៉េរិកលើគោលដៅបណ្តាញនុយក្លេអ៊ែរ។ ប្រសិនបើច្រកនេះត្រូវបានបិទ តម្លៃប្រេងសកលនឹងឡើងខ្ពស់ខ្លាំង ហើយនឹងប៉ះពាល់ដល់សេដ្ឋកិច្ចជាច្រើន ជាពិសេស ប្រទេសចិន ដែលទិញប្រេងពីអ៊ីរ៉ង់ជាង ៩០% នៃការនាំចេញរបស់អ៊ីរ៉ង់។ ទោះបីជាអ៊ីរ៉ង់អាចនឹងទទួលការប៉ះពាល់សេដ្ឋកិច្ចផ្ទាល់ខ្លួនក៏ដោយ ការបិទច្រកអាចត្រូវបានប្រើជាមធ្យោបាយឆ្លើយតប។ នាវាចម្បាំងទី៥ របស់អាម៉េរិក (U.S. Fifth Fleet) កំពុងរក្សាសុវត្ថិភាពនៃការដឹកជញ្ជូនតាមផ្លូវទឹកនេះ។ នាវាដឹកប្រេងខ្លះបានត្រលប់វិញ ដោយសារតែភាពតានតឹងថ្មីៗនេះ។ ប្រភព៖ [The Guardian]

## សង្ខេបព្រឹត្តិការណ៍សំខាន់ៗ នៃជម្លោះពន្ធគយអាម៉េរិក-ចិនឆ្នាំនេះ

- ថ្ងៃទី៤ ខែកុម្ភៈ៖ អាម៉េរិកដាក់ពន្ធនាំចូល ១០% លើទំនិញចិនទាំងអស់ ពាក់ព័ន្ធនឹងបញ្ហាថ្នាំ (opioids)។ ចិនឆ្លើយតបដោយដាក់ពន្ធលើធ្យូងថ្ម ឧស្ម័នធម្មជាតិរាវ (LNG) និងម៉ាស៊ីនកសិកម្មពីអាម៉េរិក។
- ថ្ងៃទី៤ ខែមីនា៖ អាម៉េរិកបន្ថែមពន្ធ ១០% ទៀត។ ចិនឆ្លើយតបជាមួយនឹងពន្ធដល់ទៅ ១៥% លើផលិតផលកសិកម្មអាម៉េរិក និងការរឹតត្បិតលើក្រុមហ៊ុនអាម៉េរិក។
- ថ្ងៃទី២ ខែមេសា៖ ប្រធានាធិបតី ត្រាំ ប្រកាសពន្ធ ៣៤% លើទំនិញចិនទាំងអស់ ដែលនឹងមានប្រសិទ្ធិភាពចាប់ពីថ្ងៃទី៩ ខែមេសា។
- ថ្ងៃទី៤–១១ ខែមេសា៖ ចិនឆ្លើយតបជាមួយពន្ធ ៣៤% ហើយដាក់ពាក្យបណ្ដឹងទៅ WTO និងដាក់កម្រិតលើការនាំចេញរ៉ែកម្រ។ អាម៉េរិកបង្កើនពន្ធដល់ ១៤៥% ខណៈដែលចិនឡើងដល់ ១២៥%។
- ថ្ងៃទី១២ ខែឧសភា៖ ទាំងពីរប្រទេសព្រមព្រៀងគ្នានៅទីក្រុងហ្សឺណែវ ដើម្បីកាត់បន្ថយអត្រាពន្ធ (អាម៉េរិកទៅ ៣០%, ចិនទៅ ១០%)។
- ថ្ងៃទី២៨ ឧសភា – ១១ មិថុនា៖ ភាពតានតឹងផ្លាស់ប្ដូរទៅជាបញ្ហាផ្នែកក្រៅពីពន្ធ ដូចជា ការរឹតបន្តឹងទិដ្ឋាការ ការហាមឃាត់នាំចេញបច្ចេកវិទ្យា និងការចរចាផ្នែកពាណិជ្ជកម្មរ៉ែកម្រជាដើម។

**ប្រភព៖ *AP***

## ចិនត្រៀមដកពន្ធនាំចេញទាំងអស់លើទំនិញនាំចូលពីអាហ្វ្រិក

ប្រទេសចិនបានប្រកាសត្រៀមខ្លួនដកពន្ធគយនាំចូលទាំងស្រុងលើទំនិញនាំចូលចំនួន ៥៣ ពីទ្វីបអាហ្វ្រិក ដែលមានទំនាក់ទំនងការទូតជាមួយ។ ការប្រកាសនេះធ្វើឡើងក្នុងកិច្ចប្រជុំសហប្រតិបត្តិការចិន-អាហ្វ្រិក ក្នុងពេលដែលមានកង្វល់ថាអាហ្វ្រិកអាចជួបប្រទះការកើនឡើងនៃពន្ធពីអាម៉េរិក។ អំឡុង ១៥ឆ្នាំចុងក្រោយនេះ ចិនគឺជាដៃគូពាណិជ្ជកម្មដ៏ធំបំផុតរបស់អាហ្វ្រិក។ នៅឆ្នាំ២០២៣ ការនាំចេញពីអាហ្វ្រិកទៅចិនមានទឹកប្រាក់ដល់ទៅ ១៧០ ប៊ីលានដុល្លារ។ សេចក្ដីថ្លែងការណ៍រួមនៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី បានរិះគន់ប្រទេសមួយចំនួន ចំពោះការរំខានដល់សេដ្ឋកិច្ចអន្តរជាតិ និងសណ្ដាប់ធ្នាប់ពាណិជ្ជកម្ម តាមរយៈការដាក់ពន្ធគយឯកតោភាគី។ **ប្រភព៖ *BBC***

## WTO Members Examine LDC Trade Interests, Trade and Development Priorities

WTO SPS Committee meeting, members agreed to launch a two-year Transparency Working Group starting November to improve SPS notifications, comment tracking, and the ePing platform. A new SPS mentoring system was also initiated to support developing and LDC members, with a pilot phase running from June 2025 to June 2026. Fifty-six specific trade concerns (STCs) were discussed, including new ones on coffee, peanuts, shrimp, and export listings. The STDF shared updates and its 2024 Annual Report, reflecting on two decades of work and alignment with its 2025–2030 strategy. **Source: *WTO***

## US-China Trade Framework Agreed and Other International Trade Stories to Know This Month

Members focused on trade priorities for least developed countries (LDCs), reviewing proposals on LDC graduation, accessions, and the future of the Enhanced Integrated Framework (EIF). Members shared experiences on green investment, climate finance, and Aid for Trade, with Canada, Japan, China, and Lao PDR highlighting support initiatives. A note on special and differential treatment under the Agriculture and TRIPS Agreements was discussed. The 2024 WTO Technical Assistance Report noted expanded activities in customs valuation, academic outreach, and WTO accessions, despite budget constraints. Members agreed to strengthen trade-development links and welcomed continued engagement. **Source: *World Economic Forum***

## This Initiative Could Cut the Cost of Global Trade By 25%

The Trade Worldwide Information Network (TWIN) Foundation, launched in May 2025, aims to make global trade digital, seamless, and inclusive. Built on open-source distributed ledger technology, TWIN enhances data sovereignty, transparency, and interoperability, potentially cutting trade costs by up to 25% and unlocking $10 trillion in value. Initially piloted in East Africa, TWIN reduced customs clearance times and trade costs significantly. The platform supports paperless trade, benefits small businesses, and promotes environmental sustainability. **Source: *World Economic Forum***

## The Strait of Hormuz: What Is It, And Why Does It Matter to Global Trade?

The Strait of Hormuz, a 33km wide waterway between Oman and Iran, is a vital global trade route through which over a fifth of the world's oil supply—around 20 million barrels daily—passes. It links the Gulf to the Gulf of Oman and the Arabian Sea. Iran's parliament approved a measure to close the strait in response to U.S. airstrikes on Iranian nuclear sites. Closing the strait would spike global oil prices and harm economies, especially China, which buys almost 90% of Iran's oil exports. While Iran risks economic self-harm, it could use closure as retaliation. The U.S. Fifth Fleet protects shipping in the area, and some tankers have already turned back following recent tensions. **Source: *The Guardian***

## A Timeline of the US-China Tariff and Trade Spat Since President Trump Took Office This Year

Feb 4: US imposes 10% tariffs on all Chinese imports over opioids; China retaliates with tariffs on US coal, LNG, and agricultural machinery. Mar 4: US adds 10% more tariffs; China responds with up to 15% on US farm goods and controls on US firms. Apr 2: Trump announces 34% tariffs on all Chinese imports, effective Apr 9. Apr 4–11: China counters with 34% tariffs, WTO case, and rare earth curbs. US increases tariffs to 145%; China raises to 125%. May 12: Both sides agree in Geneva to reduce tariffs (US to 30%, China to 10%). May 28–Jun 11: Tensions shift to nontariff issues—visa restrictions, tech export curbs, and rare earth trade negotiations. ***Source: AP***

## China Ready to Drop All Tariffs on African Imports

China has announced its readiness to drop all tariffs on imports from the 53 African countries with which it has diplomatic ties. The announcement came during a China-Africa co-operation meeting, amid concerns that Africa may face increased tariffs from the US. China has been Africa's largest trading partner for the past 15 years, with $170 billion in African exports to China recorded in 2023. A joint ministerial statement from the meeting criticised certain countries for disrupting the international economic and trade order through the unilateral imposition of tariffs. ***Source: BBC***

# About the iTrade

iTrade Bulletin is an e-publication by the Trade Training and Research Institute of the Ministry of Commerce. This monthly bulletin provides brief updates on specific issues in Cambodia, the regions and the world.

This knowledge-sharing through scientific researches in the multifaceted areas aims to highlight current trade news & statistics relevant to all social stakeholders.


## Honorable President

H.E. Mrs. CHAM Nimul

## Editorial Board

- H.E. Ms. SEREI Borapich
- Mr. HOR lengchhay
- Ms. PHAL Yita

## Advisor

- H.E. Mr. PENN Sovicheat
- H.E. Prof. Shandre Mugan THANGAVELU

## Teamwork

- Mr. PAO Phireak
- Ms. YANGNY Chakriya
- Mr. LY Rithy


## Announcement

Academicians, researchers, students and public are welcome to contribute their academic works, on all disciplines and topics of relevant interest to trade, to the next publication of the iTrade Bulletin.

## Topics Covered:

•International trade and logistics / trade laws;
•Digital economy / e-commerce;
•Economics and economic laws;
•Value added supply chains and logistics; and
•Facilitate the green business transition

## Categories:

•Research articles
•Case reports
•Policy Briefs


## Trade Training and Research Institute

Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA

ttri.moc | www.ttri.moc.gov.kh | @ttrimoccambodia